**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលរចនាសម្ព័ន្ធនាយកដ្ឋានបឋម និង មត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានកែសម្រួលរចនាសម្ព័ន្ធនាយកដ្ឋានបឋម និងមត្តេយ្យសិក្សា ជាពីរនាយកដ្ឋាន គឺ នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ចំណុះអគ្គនាយកដ្ឋានអប់រំ នៃ ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា២ ・ —

នាយកដ្ឋាននីមួយៗ មានមុខងារ និង ភារកិច្ចដូចខាងក្រោម :

**ក. នាយកដ្ឋានបឋមសិក្សា**

-អភិវឌ្ឍអប់រំបឋមសិក្សា សំរាប់ការអប់រំសំរាប់ទាំងអស់គ្នា

-លើកទិសដៅកសាងផែនការអភិវឌ្ឍអប់រំបឋមសិក្សារយៈពេលវែង មធ្យម ខ្លី

-កែលំអការអប់រំបឋមសិក្សា ដើម្បីធានាការចូលរៀនប្រកបដោយសមធម៌ និងគុណភាពអប់រំ ប្រកបដោយប្រសិទ្ធភាព

-កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍការអប់រំបឋមសិក្សា

-គ្រប់គ្រង និង ត្រួតពិនិត្យដំណើរការសិក្សានៅគ្រប់គ្រឹះស្ថានបឋមសិក្សារដ្ឋ និង ឯកជនលើការងាររដ្ឋបាល និងបច្ចេកទេស

-តាមដានត្រួតពិនិត្យ និងកែលំអការអនុវត្តកម្មវិធីសិក្សា បច្ចេកទេសគរុកោសល្យ

-សិក្សាសំណើសុំបង្កើត បើក និងទទួលស្គាល់សាលាបឋមសិក្សារដ្ឋ និងឯកជន និងសំណើបង្រៀន ថ្នាក់ពីរពេល ថ្នាក់គួប

**ខ. នាយកដ្ឋានអប់រំកុមារតូច**

-អភិវឌ្ឍអប់រំកុមារតូច (០-៦ ឆ្នាំ) សំរាប់ការអប់រំសំរាប់ទាំងអស់គ្នា

-លើកទិសដៅកសាងផែនការអភិវឌ្ឍអប់រំកុមារតូច រយៈពេលវែង មធ្យម ខ្លី ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងសហគមន៍

-កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រងនិង អភិវឌ្ឍវិស័យអប់រំកុមារតូច

-គ្រប់គ្រង និងត្រួតពិនិត្យថ្នាក់ និង សាលាមត្តេយ្យសិក្សា ទាំងរដ្ឋ និងឯកជនលើការងាររដ្ឋបាល និងបច្ចេកទេស

-ជំរុញការអភិវឌ្ឍមត្តេយ្យសហគមន៍ ទារកដ្ឋាន និង ជំរុញគោលការណ៍អប់រំសហគមន៍ (ម្តាយ) ដើម្បីធានាថែទាំកុមារ ទាំងសុខភាព ទាំងបញ្ញា ដោយសហការជាមួយ ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និង សហគមន៍

-តាមដានត្រួតពិនិត្យ និងកែលំអ ការអនុវត្តកម្មវិធីសិក្សា បច្ចេកទេសគរុកោសល្យ

-សិក្សាសំណើសុំបង្កើត បើក និងទទួលស្គាល់សាលាមត្តេយ្យសិក្សារដ្ឋ និងឯកជន និងសំណើផ្សេងៗ ពាក់ព័ន្ធមត្តេយ្យសិក្សា និងទារកដ្ឋាន

**មាត្រា៣ ‧ –**

នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការ មួយរូប រឺ ច្រើនរូបតាមការចាំបាច់ ។

**មាត្រា៤ ‧ –**

ភារកិច្ចជាក់ស្តែង និង រចនាសម្ព័ន្ធរបស់ នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៥ ‧ –**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៦ ‧ –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ តុលា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៦ “ ដើម្បីអនុវត្ត ”

-ឯកសារ-កាលប្បវត្តិ